**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
លេខ: ១៤៧១ សជណ

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៤

# ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ជម្រាបជូន

**-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងបរិស្ថាន**
**-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តមណ្ឌលគិរី**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តក្រចេះ**

**កម្មវត្ថុ ៖** របាយការណ៍ស្តីពីលទ្ធផល នៃកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ចចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤។

**យោង ៖** ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូន **ឯកឧត្តម** ជ្រាបថា៖ ចំពោះរបាយការណ៍របស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤ ទាក់ទងដល់ការវាយតម្លៃក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន **១១** ក្នុងនោះនៅខេត្តមណ្ឌលគិរីចំនួន **០៣** នៅខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុចំនួន **០៣** នៅខេត្តបន្ទាយមានជ័យចំនួន **០១** នៅខេត្តព្រះវិហារ និងខេត្តកំពង់ធំចំនួន **០១** នៅខេត្តឧត្តរមានជ័យចំនួន **០១** នៅខេត្តបាត់ដំបងចំនួន **០១** និងនៅខេត្តក្រចេះចំនួន **០១** រាជរដ្ឋាភិបាលសម្រេចដូចខាងក្រោម៖

**I- ក្រុមហ៊ុន កសិកម្មខ្មែរអង្គរ ខូអិលធីឌី** (KASEKAM KHMER ANGKOR Co.,Ltd)

១- និរាករណ៍លិខិតលេខ **១០០៤ សជណ** ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលផ្តល់គោលការណ៍វិនិយោគដល់ក្រុមហ៊ុន **កសិកម្មខ្មែរអង្គរ** (KASEKAM KHMER

ANGKOR CO.,Ltd) លើផ្ទៃដីទំហំ **៩.១៦០ ហិកតា (ប្រាំបួនពាន់មួយរយហុកសិបហិកតា)** ក្នុងដែនជម្រកសត្វព្រៃភ្នំព្រេច ភូមិសាស្ត្រខេត្តមណ្ឌលគិរី។

២- និរាករណ៍អនុក្រឹត្យលេខ **២០៥ អនក្រ.បក** ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព។

៣- ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូនដែនជម្រកសត្វព្រៃភ្នំព្រេច ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន។

៤- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តមណ្ឌលគិរី រៀបចំបែបបទបច្ចេកទេស ដើម្បីគ្រប់គ្រងផ្ទៃដីដែលបានដកហូតស្របតាមលិខិតបទដ្ឋានជាធរមាន។

## II- ក្រុមហ៊ុន អិល.ខេ.អិល ខនស្រ្តាក់សិន ខូអិលធីឌី (L.K.L CONSTRUCTION CO., LTD)

១- និរាករណ៍លិខិតលេខ **៤៨១ សជណ** ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលផ្តល់ជាគោលការណ៍វិនិយោគដល់ក្រុមហ៊ុន **អិល.ខេ.អិល ខនស្រ្តាក់សិន ខូអិលធីឌី** (L.K.L CONSTRUCTION CO., LTD) លើផ្ទៃដីទំហំ **៥.៥៥៩ ហិកតា (ប្រាំពាន់ប្រាំរយហាសិបប្រាំបួនហិកតា)** ក្នុងដែនជម្រកសត្វព្រៃភ្នំណាមលៀរ ភូមិសាស្ត្រខេត្តមណ្ឌលគិរី។

២- និរាករណ៍អនុក្រឹត្យលេខ **៩១ អនក្រ.បក** ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព។

៣- ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូនដែនជម្រកសត្វព្រៃភ្នំណាមលៀរ ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន។

៤- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តមណ្ឌលគិរី រៀបចំបែបបទបច្ចេកទេស ដើម្បីគ្រប់គ្រងផ្ទៃដីដែលបានដកហូតស្របតាមលិខិតបទដ្ឋានជាធរមាន។

## III- ក្រុមហ៊ុន ឫទ្ធី គិរី សីមា

១- និរាករណ៍លិខិតលេខ **២៧៩ សជណ** ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលផ្តល់គោលការណ៍វិនិយោគដល់ក្រុមហ៊ុន **ឫទ្ធី គិរី សីមា** លើផ្ទៃដីទំហំ **៥.០០០ ហិកតា (ប្រាំពាន់ហិកតា)** ក្នុងដែនជម្រកសត្វព្រៃស្នួល ភូមិសាស្ត្រ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី និងសិទ្ធិប្រទានលេខ **១៩១.សប្រទ** ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល។

២- លុបក្រុមហ៊ុន **ឫទ្ធី គិរី សីមា** លើផ្ទៃដីទំហំ **៥.០០០ ហិកតា (ប្រាំពាន់ហិកតា)** ក្នុងដែនជម្រកសត្វព្រៃស្នួល ភូមិសាស្ត្រ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ចេញពីអនុក្រឹត្យលេខ **១២៨ អនក្រ.បក** ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងនិរាករណ៍អនុក្រឹត្យលេខ **១២០ អនក្រ.បក** ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៥.០០០ ហិកតា (ប្រាំពាន់ហិកតា)** ស្ថិតក្នុងដែនជម្រកសត្វព្រៃស្នួល ស្រុកកែវសីមា ខេត្តមណ្ឌលគិរី។

## IV- ក្រុមហ៊ុន ញូ ខសម៉ូស ឌីវេឡុបមេន (ខេមបូឌា) ខមភេនី លីមិតធីត

១- និរាករណ៍លិខិតលេខ **៥៣៧. សជណ** ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលរាជរដ្ឋាភិបាលបានឯកភាពជាគោលការណ៍ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដាក់ប្រជុំ

ច្រកចេញ-ចូលតែមួយ របស់ក្រុមហ៊ុន **ញូ ខសម៉ូស ឌីវេឡុបមេន (ខេមបូឌា) ខមភេនី លីមីតធីត** លើផ្ទៃដីទំហំ **៩០០ ហិកតា** នៅតំបន់ទឹកពុះ ភូមិទេទឹកពុះ ឃុំឆ្លង ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។

២- ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូនដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន។

៣- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តកំពង់ស្ពឺ រៀបចំបែបបទបច្ចេកទេស ដើម្បីគ្រប់គ្រងផ្ទៃដីដែលបានដកហូតស្របតាមលិខិតបទដ្ឋានជាធរមាន។

V- **ក្រុមហ៊ុន JIANKING ( Cambodia ) International Investment Co.,Ltd**

១- និរាករណ៍លិខិតលេខ **១៥៨១ សជណ** ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១១ របស់ទីស្ដីការគណៈរដ្ឋមន្ត្រីដែលផ្ដល់គោលការណ៍វិនិយោគដល់ក្រុមហ៊ុន **JIANKING ( Cambodia ) International Investment Co.,Ltd** លើផ្ទៃដីទំហំ **៨.៥៦៨ ហិកតា (ប្រាំបីពាន់ប្រាំរយហុកសិបប្រាំបីហិកតា)** ស្ថិតនៅក្នុងឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ **"គិរីរម្យ"** ភូមិសាស្ត្រខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ និងសិទ្ធិប្រទានលេខ **៨៧.សប្រទ** ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១២ របស់រាជរដ្ឋាភិបាល ។

២- និរាករណ៍អនុក្រឹត្យលេខ **០៣ អនក្រ.បក** ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១២ ស្ដីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យលេខ **៤៣ អនក្រ.បក** ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១២ ស្ដីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៨.៥៦៨ ហិកតា** ក្នុងឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ**"គិរីរម្យ"** ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ។

៣- ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូនឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ **"គិរីរម្យ"** ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន។

៤- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ រៀបចំបែបបទបច្ចេកទេស ដើម្បីគ្រប់គ្រងផ្ទៃដីដែលបានដកហូតស្របតាមលិខិតបទដ្ឋានជាធរមាន។

VI- **ក្រុមហ៊ុន គិរីរម្យ អេកូទូរីសឹម អ៊ីនវេសមេន**

១- ប្រគល់ជូនក្រសួងបរិស្ថានបំពេញនីតិវិធីបន្តជូនក្រុមហ៊ុន **គិរីរម្យ អេកូទូរីសឹម អ៊ីនវេសមេន** ដោយពិនិត្យផ្ដល់ជូនទំហំដីចំនួន **២០ ហិកតា (ម្ភៃហិកតា)** នៃផ្ទៃដីដែលនៅសេសសល់ ហើយនឹងត្រូវកំណត់ក្នុងកិច្ចសន្យាសម្រាប់ធ្វើការវិនិយោគវិស័យទេសចរណ៍ធម្មជាតិ។

២- កែសម្រួលអនុក្រឹត្យលេខ **១៧៣ អនក្រ.បក** ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩ ស្ដីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យលេខ **០៨. អនក្រ.បក** ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១០ ស្ដីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៦០៩ ហិកតា** ក្នុងឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ**"គិរីរម្យ"** ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ។

៣- ប្រគល់ផ្ទៃដីដែលនៅសេសសល់ពីការកាត់ចេញពីក្រុមហ៊ុនទាំងអស់ ជូនឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ **"គិរីរម្យ"** ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន។

៤- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ចក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តកំពង់ស្ពឺ រៀបចំបែបបទបច្ចេកទេស ដើម្បីគ្រប់គ្រងផ្ទៃដីដែលបានដកហូតស្របតាមលិខិតបទដ្ឋានជាធរមាន។

VII- **ក្រុមហ៊ុន សំណង់ លាងប៊ូ** (Leang Bou Construction Co.,Ltd)

១- និរាករណ៍លិខិតលេខ **១៦២០ សជណ** ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលផ្តល់ជាគោលការណ៍វិនិយោគដល់ក្រុមហ៊ុន **សំណង់ លាង ប៊ូ (Leang Bou Construction Co.,Ltd)** លើផ្ទៃដីទំហំ **១.៧៨៣ ហិកតា (មួយពាន់ប្រាំពីររយប៉ែតសិបបីហិកតា)** ក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃតំបន់ការពារទេសភាពបន្ទាយឆ្មារ ភូមិសាស្ត្រ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។

២- ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូនតំបន់ប្រើប្រាស់ដោយចីរភាព នៃតំបន់ការពារទេសភាពបន្ទាយឆ្មារ ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន។

៣-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តបន្ទាយមានជ័យ រៀបចំបែបបទបច្ចេកទេស ដើម្បីគ្រប់គ្រងផ្ទៃដីដែលបានដកហូតស្របតាមលិខិតបទដ្ឋានជាធរមាន។

VIII- **ក្រុមហ៊ុន ស្រី បញ្ញា អភិវឌ្ឍន៍ ខូអិលធីឌី**

១- និរាករណ៍លិខិតលេខ **១១៧៣ សជណ** ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលផ្តល់ជាគោលការណ៍វិនិយោគដល់ក្រុមហ៊ុន **ស្រី បញ្ញា អភិវឌ្ឍន៍ ខូអិលធីឌី** លើផ្ទៃដីទំហំ **៥៨៨ ហិកតា (ប្រាំរយប៉ែតសិបប្រាំបីហិកតា)** ក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ភូមិសាស្ត្រខេត្តព្រះវិហារ និងខេត្តកំពង់ធំ។

២- និរាករណ៍អនុក្រឹត្យលេខ **២១៧ អនក្រ.បក** ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព របស់រាជរដ្ឋាភិបាល។

៣-ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូនដែនជម្រកសត្វព្រៃបឹងពែរ ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន។

៤- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តព្រះវិហារ និងខេត្តកំពង់ធំ រៀបចំបែបបទបច្ចេកទេស ដើម្បីគ្រប់គ្រងផ្ទៃដីដែលបានដកហូតស្របតាមលិខិតបទដ្ឋានជាធរមាន។

IX- **ក្រុមហ៊ុន ឃុន សៀ អ៊ឹមផត អិចផត**

១- និរាករណ៍លិខិតលេខ **៥៨៣ សជណ** ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលផ្តល់គោលការណ៍វិនិយោគដល់ក្រុមហ៊ុន **ឃុន សៀ អ៊ឹមផត អិចផត** លើផ្ទៃដីទំហំ **៨.២០០ ហិកតា (ប្រាំបីពាន់ពីររយហិកតា)** ក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ភូមិសាស្ត្រ ខេត្តឧត្តរមានជ័យ និងសិទ្ធិប្រទានលេខ **៩០.សប្រទ** ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១២ របស់រាជរដ្ឋាភិបាល។

២- និរាករណ៍អនុក្រឹត្យលេខ **៧៨ អនក្រ.បក** ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យលេខ **១២៥ អនក្រ.បក** ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៨.២០០ ហិកតា** ក្នុងតំបន់ដែនជម្រកសត្វព្រៃ គូលែន-ព្រហ្មទេព ភូមិសាស្ត្រខេត្តឧត្តរមានជ័យ។

X- **ក្រុមហ៊ុន** BSC Import Export Co., Ltd

១- និរាករណ៍លិខិតលេខ **៥៨៤ សជណ** ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលផ្តល់គោលការណ៍វិនិយោគដល់ក្រុមហ៊ុន BSC Import Export Co., Ltd លើផ្ទៃដីទំហំ **៤.៥៥៧ ហិកតា (បួនពាន់ប្រាំរយហាសិបប្រាំពីរហិកតា)** ក្នុងតំបន់ដែនជម្រកសត្វព្រៃរនាមដូនសំ

ភូមិសាស្ត្រ ស្រុកភ្នំព្រឹក និងស្រុកកំរៀង ខេត្តបាត់ដំបង និងសិទ្ធិប្រទានលេខ **៩១.សប្រទ** ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១២ របស់រាជរដ្ឋាភិបាល។

២- និរាករណ៍អនុក្រឹត្យលេខ **៩០ អនក្រ.បក** ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យលេខ **១២៧.អនក្រ.បក** ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៤.៥៥៧ ហិកតា** ក្នុងតំបន់ដែនជម្រកសត្វព្រៃរនាមដូនសំ ក្នុងភូមិសាស្ត្រស្រុកភ្នំព្រឹក និងស្រុកកំរៀង ខេត្តបាត់ដំបង។

**XI- ក្រុមហ៊ុន ធីធីវ៉ាយ អភិវឌ្ឍន៍ ដំណាំកសិកម្ម ខូអិលធីឌី**

១- ផ្តល់សម្បទានដីសេដ្ឋកិច្ចតែចំនួន **២១៥ ហិកតា (ពីររយដប់ប្រាំហិកតា)** ជូនក្រុមហ៊ុន **ធីធីវ៉ាយ អភិវឌ្ឍន៍ ដំណាំកសិកម្ម ខូអិលធីឌី** ដែលបានដាំកៅស៊ូរួច។ ចំពោះដីដែលនៅសល់ពីការផ្តល់ជូនប្រជាពលរដ្ឋតាមបទបញ្ជាលេខ **០១ បប** ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១២ និងដីចំនួន **២១៥ ហិកតា** ខាងលើ ស្ថិតក្នុងដែនជម្រកសត្វព្រៃស្នួល ភូមិសាស្ត្រ ឃុំពីរធ្នូ ស្រុកស្នួល ខេត្តក្រចេះ ត្រូវប្រគល់ជូនក្រសួងបរិស្ថានគ្រប់គ្រង។

២- កែសម្រួលអនុក្រឹត្យលេខ **១៧៣ អនក្រ.បក** ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យលេខ **១២៥.អនក្រ.បក** ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១០ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៩.៧៨០ ហិកតា** ក្នុងដែនជម្រកសត្វព្រៃស្នួល ភូមិសាស្ត្រឃុំពីរធ្នូ ស្រុកស្នួល ខេត្តក្រចេះ។

៣- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តក្រចេះ រៀបចំបែបបទបច្ចេកទេស ដើម្បីគ្រប់គ្រងផ្ទៃដីដែលដកហូតស្របតាមលិខិតបទដ្ឋានជាធរមាន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** ជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

**ឋ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**គីករ៉េត សំរេច**

**ចម្លងជូន៖**
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម-លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- សមាជិកគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច
- ឯកសារ-កាលប្បវត្តិ